**BMI0017**

# សម្ភាសន៍ជាមួយឈ្មោះហ៊ូ អ៊ីម ភេទស្រី អាយុ៥៣ឆ្នាំ

មុខងារជំនាន់ខ្មែរក្រហម«នារីតម្បាញ»

មុខងារបច្ចុប្បន្ន«កសិករ»

ស្រុកកំណើតនៅភូមិចុងខ្នង ឃុំមហាខ្នង ស្រុកកោះសូទិន ខេត្តកំពង់ចាម

រស់នៅភូមិត្រសេកជ្រំ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ សុខ វណ្ណៈ

០១:០២:៥២

៣០ទំព័រ

វណ្ណៈ ខ្ញុំជំរាបមីងម្តងទៀតថាខ្ញុំឈ្មោះសុខ វណ្ណៈមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។

អ៊ីម : ចាស ។

វណ្ណៈ ខ្ញុំមកនេះចង់បានពត៍មានទាក់ទងនិងស្រុកម៉ាឡៃតាំងពីឆ្នាំ៧៩មកតើមានរឿងរ៉ាវអ្វីកើតឡើងខ្លះនៅក្នុស្រុកម៉ាឡៃយើងនេះ?

អ៊ីម : ចាស ។

វណ្ណៈ ហើយខ្ញុំធ្វើការសម្ភាសន៍ជាមួយមីងហ្នឹង តើមីងអនុញ្ញាតឲ្យខ្ញុំយកទៅសរសេរចងក្រងឲ្យក្មេងៗជំនាន់ក្រោយដឹងឮបានទេ ពីស្រុកម៉ាឡៃយើងបានទេ?

អ៊ីម : ចាស!មានអី ។

វណ្ណៈ ចឹងមីងមិនថាអីទេ?

អ៊ីមៈ ចាស ។

វណ្ណៈ ចឹងមីងឈ្មោះអីដែរ?

អ៊ីម : ខ្ញុំឈ្មោះហ៊ូ អ៊ីម ។

វណ្ណៈ ចឹងមីងមានឈ្មោះហៅក្រៅទេ?

អ៊ីម : អត់មាន ។

វណ្ណៈ ចឹងជំនាន់ខ្មែរក្រហមច្រើនប្រើឈ្មោះពីរ?

អ៊ីម : ខ្ញុំមិនដែលប្រែក្លាចម៉ែរកមិនឃើញ ។

វណ្ណៈ ចឹង?

អ៊ឹម ៖ ចាស ។

វណ្ណៈ ចឹងមីងមានអាយុប៉ុន្មានហើយ?

អ៊ឹម ៖ ខ្ញុំអាយុ៥៣ ។

វណ្ណៈ ឪពុកមីងឈ្មោះអី?

អ៊ឹម ៖ ឪពុកខ្ញុំឈ្មោះហ៊ូ វ័ន ។

វណ្ណៈ ម្តាយ?

អ៊ឹម ៖ ជឹម ថុន ។

វណ្ណៈ មានបងប្អូនទាំងអស់ប៉ុន្មាននាក់?

អ៊ឹម ៖ មានបងប្អូនទាំងអស់១៣នាក់ ។

វណ្ណៈ សព្វថ្ងៃនៅសល់ប៉ុនាន?

អ៊ឹម ៖ នៅសល់៩នាក់ ។

វណ្ណៈ ចុះប៉ុន្មាននាក់ទៀតស្លាប់នៅពេលណា?

អ៊ឹម ៖ ប៉ុន្មាននាក់ហ្នឹងស្លាប់នៅឆ្នាំ៩៧ ។

វណ្ណៈ គាត់ស្លាប់ដោយសារអី?

អ៊ឹម ៖ ដោយសារជំងឺគ្រុនចាញ់ ក្រោយមកទៀតឆ្នាំ២០០៣ស្លាប់ដោយជំងឺអេត ។

វណ្ណៈ ចឹងកាលជំនាន់ប៉ុល ពតមិនអាអីទេ?

អ៊ឹម ៖ ចាស!អត់មានអីទេ ។

វណ្ណៈ ចឹងស្រុកកំណើតមីងនៅណាដែរ?

អ៊ឹម ៖ ខ្ញុំនៅស្រុកកោះសូទិន ។

វណ្ណៈ ឃុំអីដែរ?

អ៊ឹម ៖ ឃុំមហាខ្ញូង ។

វណ្ណៈ ឃុំមហាខ្ញូង?

អ៊ឹមៈ ចាស ។

វណ្ណៈ ចឹងមីងមានចាំភូមិទេ?

អ៊ឹម ៖ ភូមិចុងខ្ញូង ។

វណ្ណៈ ខេត្តកំពង់ចាម?

អ៊ឹម ៖ ចាស ។

វណ្ណៈ ចឹងបច្ចុប្បន្នមីងមករស់នៅភូមិអី?

អ៊ឹម ៖ ភូមិត្រសេកជ្រុំ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ។

វណ្ណៈ ខេត្តបន្ទាយមានជ័យ?

អ៊ឹម ៖ ចាស ។

វណ្ណៈ ចឹងបងប្អូនមីងមានប្រុសស្រីប៉ុន្មាននាក់?

អ៊ឹម ៖ មានប្រុស៥ ស្រី៨ ។

វណ្ណៈ ចឹងឪពុកមីងស្លាប់ហើយ ។

វណ្ណៈ ចឹងស្រីច្រើនជាង?

អ៊ឹមៈ ស្រីច្រើនជាង ។

វណ្ណៈ ចឹងឪពុកមីងស្លាប់ហើយ?

អ៊ឹម ៖ ឪពុកខ្ញុំស្លាប់កាលឆ្នាំ២០០០ នៅម្ដាយរស់នៅរាល់ថ្ងៃ ។

វណ្ណៈ ចឹងខ្ញុំចង់ឲ្យមីងនិយាយរឿងរ៉ាវដូចថាថាមីងរត់មកតាមផ្លូវយួនវៃចូលទីក្រុងភ្នំពេញ ហើយមីងរត់មកជួបហេតុការណ៍អីខ្លះសូមមីងជួយរៀបរាប់ត្រួសៗ?

អ៊ឹម ៖ជួបនៅពេលគេបាញ់គ្នាមានគ្រាប់ផ្លោងចឹងមកទៅខ្ញុំរត់បែកគ្នាចឹងទៅ ខ្ញុំហែលទឹកផងអីផងស្ពាយសាក់កាដូអត់មានស្បែកជើងដើរកាត់តាមព្រៃហ្នឹង ។

វណ្ណៈ ចឹងមីងចេះហែលទឹកដែរ?

អ៊ឹម ៖ ចាស ។

វណ្ណៈ ចឹងឆ្លងទឹក?

អ៊ឹមៈ កាលហ្នឹងឆ្លងទឹកស្ទឹង ។

វណ្ណៈ ស្ទឹងអីគេ?

អ៊ឹម ៖ កាលហ្នឹងគេហៅទ្រុងទាៗ មកហួសពីចំណោមរោងគោមក ។

វណ្ណៈ មីងរត់យ៉ាងម៉េចខ្លះ?

អ៊ឹម ៖ រត់គេបាញ់បន្តៗពីក្រោយទៅ រត់តែពីរនាក់មកបានជួបនិងយោធា ។

វណ្ណៈ យោធាខាងណា?

អ៊ឹម ៖ ខាងខ្មែរក្រហម ។

វណ្ណៈ ចឹងកាលហ្នឹងយួនដេញបាញ់រហូត?

អ៊ឹម ៖ ចាស ។

វណ្ណៈ ចឹងកាលរត់ហ្នឹងប្រើរយៈពេលប៉ុន្មានបានមកដល់ម៉ាឡៃ?

អ៊ឹម ៖ កាលហ្នឹងប្រហែលជាបីខែ ។

វណ្ណៈ រត់កាត់តាមបែកចានឬតាមណាខ្លះ?

អ៊ឹម ៈ រត់កាត់តាមបែកចានរួចចេញមកខាងខេត្តពោធិសាត់បាត់ដំបងរហូតដល់ភ្នំស្ដោភ្នំអីហ្នឹង ។

វណ្ណៈ បាទ ។

អ៊ឹម ៈ ហើយមកដល់កោះក្រឡហើយមកតាមផ្លូវមានមនុស្សស្លាប់ច្រើន ។

វណ្ណៈ ចឹងកាលហ្នឹងរត់កាត់ពោធិសាត់និងបាត់ដំបង?

អ៊ឹមៈ ចាស! កោះក្រឡហើយភ្នំស្ដោហ្នឹង ។

វណ្ណៈ ចឹងភ្នំស្ដោមានដឹងថានៅខេត្តណា?

អ៊ឹម ៈ មិនដឹងជាខេត្តណាទេ មិនដឹងជាពោធិសាត់ឬបាត់ដំបងខ្ញុំមិនសូវស្គាល់ដែរ ។

វណ្ណៈ ចឹងនៅតាមផ្លូវមានមនុស្សស្លាប់ដែរ?

អ៊ឹម ៈ មានពេលគេបាញ់ហើយអីហើយ ខ្ញុំមកឃើញគេរៃក្ដៅៗតែខ្ញុំមកឃើញមនុស្សស្លាប់នៅទីនោះរន្ទូករនែល ។

វណ្ណៈ ចឹងរត់បីខែហ្នឹងមកដល់ព្រំដែនម៉ាឡៃហ្នឹង?

អ៊ឹម ៈ នៅក្នុងស្រុកម៉ាឡៃដែរ ខ្ញុំមកដល់បឹងបេង ។

វណ្ណៈ ចឹងមកដល់ម៉ាឡៃចឹងបេង?

អ៊ឹមៈ ចាស ។

វណ្ណៈ ចឹងពេលដល់ម៉ាឡៃបឹងបេងហើយមីងរត់ទៅណាទៀត?

អ៊ឹម ៈ ត្រឡប់ទៅក្រោយវិញ ទៅខាងត្រាងទៅខាងភ្នំព្រឹកភ្នំអីហ្នឹងពេជ្រចិន្ដាហ្នឹង ។

វណ្ណៈ ចឹងកាលហ្នឹងមានការប្រកាសប្រមូលទ័ពឡើងវិញឬមួយយ៉ាងម៉េច?

អ៊ឹម ៈ កាលហ្នឹងចេះតែរត់ៗទៅក្រោយមកបានគេប្រមូលដឹកជញ្ជូនឡើងវិញ ។

វណ្ណៈ ចឹងនៅឆ្នាំ៧៩ហ្នឹងដែរ?

អ៊ឹម ៈ ចាស ។

វណ្ណៈ ប្រហែលជាខែប៉ុន្មានគេប្រមូលកំលាំងទ័ពខ្មែរក្រហមមានបក្សអីខ្លះកាល៧៩?

អ៊ឹម ៈ មានតែខ្មែរក្រហមមួយ ។

វណ្ណៈ ចុះមានមូលីណាការ សេរីការអីនោះ?

អ៊ឹម ៈ មិនទាន់មានទេ កាលហ្នឹង ។

វណ្ណៈ ចឹងមិនទាន់មានទេកាល៧៩?

អ៊ឹមៈ ចាស ។

វណ្ណៈ ចឹងនៅឆ្នាំ១៩៧៩មានតែទ័ពខ្មែរក្រហមទេ?

អ៊ុមៈ ចាស ។

វណ្ណៈ ចឹងមិនទាន់មានកងទ័ពផ្សេងទេ យូរៗ បានមានកងទ័ពសេរីការប៉ារាអី?

អ៊ុមៈ ហ្នឹងវត់ចេញមកពីភ្នំពេញយើងមកនៅនិងសហករណ៍គេបានមាន គេហៅថាខ្មែរសអីណា ។

វណ្ណៈ ចឹងខ្ញុំចង់និយាយកាលវត់៧៩ហ្នឹង?

អ៊ុមៈ ចាស ។

វណ្ណៈ នៅពេលកងកំលាំងប្រមូលបានឡើងវិញហ្នឹង៧៩ហ្នឹងមានទីតាំងឈរជើងនៅត្រង់ណាដែរ?

អ៊ុម ៈ នៅតាមមើលគេប្រមូលគ្នានៅដឹកជញ្ជូនហ្នឹងនៅត្រាង ។

វណ្ណៈ នៅត្រាង?

អ៊ុមៈ ចាស ។

វណ្ណៈ ប្រមូលយ៉ាងម៉េច?

អ៊ុមៈ នៅតាមកងចឹងទៅ ។

វណ្ណៈ នៅត្រាង?

អ៊ុមៈ ចាស ។

វណ្ណៈ ត្រាងនៅខាងបន្ទាយមានជ័យនៅម៉ាឡៃហ្នឹង?

អ៊ុម ៈ អត់ទេ ត្រាងនៅខាងបាត់ដំបងអីត្រាងនោះ ។

វណ្ណៈ ចឹងនៅខាងបាត់ដំបង?

អ៊ុមៈ ចាស ។

វណ្ណៈ កាលហ្នឹងមេបញ្ជាការឈ្មោះអីជាអ្នកប្រមូលហ្នឹង?

អ៊ុម ៈ ខ្ញុំមិនសូវស្គាល់ទេ តែតាមកងដឹកជញ្ជូនពីភ្នំពេញមកខ្ញុំស្គាល់ តាមកងដឹកជញ្ជូនពីភ្នំពេញមកហ្នឹង ពួករោងចក្រហ្នឹងបងផលគាត់ជាអ្នកប្រមូលកំលាំងឡើងវិញ ។

វណ្ណៈ បងផលហ្នឹងស្រី?

អ៊ុម ៈ ចាស ។

វណ្ណៈ ចឹងគាត់ជាអ្នកប្រមូលកំលាំង?

អ៊ុម ៈ គាត់ជាអ្នកប្រមូលកំលាំងដឹកជញ្ជូនស្បៀងទៅឲ្យទ័ពខាងមុខ ។

វណ្ណៈ ដឹកស្បៀងឲ្យទ័ព?

អ៊ុមៈ ចាស ។

វណ្ណៈ ដឹកស្បៀងយកឲ្យទ័ពដើម្បីវ៉ៃជាមួយទាហានរដ្ឋាភិបាយ យួនហ្នឹង?

អ៊ុម ៈ ចាស ។

វណ្ណៈ   ចឹងពេលដែលនៅជាមួយយួនហ្នឹងមីងមានឃើញទាហានយួនស្លាប់ច្រើនទេ?

អ៊ីម ៖  មាន  សុទ្ធតែក្មេងៗ ។

វណ្ណៈ   ទាហានយួន?

អ៊ីមៈ   ចាស ។

វណ្ណៈ   ចឹងទាហានយួនមកដល់ហ្នឹងដែរ?

អ៊ីម ៖  មកដល់នៅត្រឹមហួសត្រាងទៅ ។

វណ្ណៈ   ចឹងយួនមានចូលមកដល់ម៉ាឡៃដែរ?

អ៊ីម ៖  ម៉ាឡៃខ្ញុំមិនដែលបានទៅទេ  ពេលយួនវៃមកខ្ញុំរត់ទៅនៅដីថៃ ។

វណ្ណៈ   នៅថៃខាងត្រាង?

អ៊ីម ៖  នៅថៃខាងម៉ាឡៃយើងហ្នឹង ។

វណ្ណៈ   ចឹងនៅថៃខាងម៉ាឡៃហ្នឹងដែរ?

អ៊ីមៈ   ចាស ។

វណ្ណៈ   មានទាហានយួនសាប់និងទាហានរដ្ឋាភិបាលខ្មែរនោះមិនមកជាមួយទាហានយួនដែរ?

អ៊ីម ៖  ចាស ។

វណ្ណៈ   មិនវៃជាមួយទាហានខ្មែរក្រហម?

អ៊ីមៈ   ចាស ។

វណ្ណៈ   ចឹងវៃទៅមានរបួសទៅរបួសមកមានស្លាប់ទៅស្លាប់មក?

អ៊ីមៈ   ចាស ។

វណ្ណៈ  ចឹងកាលហ្នឹងមានទាហានខ្មែរ?

អ៊ីមៈ   ចាស!នៅខាងខ្មែរក្រហមគេហៅខ្មែរក្រហម ។

វណ្ណៈ   ហ្នឹងហើយ?

អ៊ីមៈ   ចាស ។

វណ្ណៈ   ចឹងកាលហ្នឹងមានស្លាប់ដូចគ្នា?

អ៊ីម ៖  ចាស!មានដូចគ្នាហ្នឹង ។

វណ្ណៈ   ចឹងដូចថាមីងមកដល់ទឹកដីដំបូងមីងមានឃើញថាឆ្នាំ៧៩ហ្នឹងមានផ្ទះអីដែរ?

អ៊ីម ៖  អត់មានទេ ។

វណ្ណៈ   គ្មានផ្ទះទេ?

អ៊ីមៈ   ចាស!  ចង់តែកៅស៊ូដេក ។

វណ្ណៈ ចឹងនៅម៉ាខ្សែនេះមិនមានផ្ទះទេ?

អ៊ឹមៈ អត់ ។

វណ្ណៈ ចឹងមានព្រៃនិងដើមឈើធំៗ ទេ?

អ៊ឹម ៖ មានដើមឈើធំៗ មានព្រៃឡើងជិតស្ទប់ចឹងទៅ ។

វណ្ណៈ ចឹងអត់មានដើមដូងដើមស្វាយដូចចឹងទេ?

អ៊ឹម ៖ អត់មានទេ នេះទើបដាំក្រោយមកទេ ។

វណ្ណៈ ហើយចឹងដើមឈើប៉ុណ្ណាៗ ទៅមីង?

អ៊ឹម ៖ ដើមឈើធំៗទំហំមួយអោបពីរអោបឯណោះ ។

វណ្ណៈ ដើមឈើដែលសម្បូរជាងគេដើមអីទៅ?

អ៊ឹម ៖ មានដើមបេង ដើមធ្នឹកកាដុង... ។

វណ្ណៈ ចឹងធំៗដូចជាបេងអីហ្នឹង?

អ៊ឹមៈ ចាស ។

វណ្ណៈ ចឹងមានគគីរ?

អ៊ឹមៈ មានបេង គគីរ ឈើទាលហ្នឹង ។

វណ្ណៈ ចឹងកាលហ្នឹងមិនទាន់ផ្ទះទេ?

អ៊ឹម ៖ ចាស!មិនទាន់មានទេ ពេលយើងមកនៅចឹងយើងកាប់ឈើកាប់ឫស្សីយកមកក្រងធ្វើជារនាប ដេកទៅតែប្រក់ដំបូងកៅស៊ូដដែរ ។

វណ្ណៈ ចឹងកាលហ្នឹងកងទ័ពខ្មែរក្រហមហ្នឹង?

អ៊ឹម ៖ ចាស!ទាំងកងទ័ពនិងនារីដឹកជញ្ជូន ។

វណ្ណៈ ចឹងមានគ្រូនចាញ់ស្លាប់ទេ?

អ៊ឹម ៖ មានគ្រូនចាញ់ស្លាប់ជារឿងធម្មតា ។

វណ្ណៈ ចឹងនៅពេលឃើញចឹងមីងភ័យទេ?

អ៊ឹម ៖ ធម្មតា ខ្ញុំឈឺជិតងាប់ដែលហ្នឹងណា ។

វណ្ណៈ ចឹងខ្មែរក្រហមរស់នៅក្នុងព្រៃ?

អ៊ឹម ៖ ចាស!ដូចគេថាមិនខុសមែន ខ្មែរក្រហមស៊ីតែស្លឹកឈើហ្នឹង តែក្រោយមមកកែប្រែជីវភាព ។

វណ្ណៈ ចឹងមានហូបស្លឹកឈើមែន?

អ៊ឹម ៖ ហូប មានស្លឹកបាតខ្លះមានវ៉ាថ្មីងចឹងទៅមានគេរលកមកបបរលាយចូលគ្នាហូបចឹងទៅធ្វើម៉េចថា ឲ្យរស់មួយគ្រាសិន ។

វណ្ណៈ ចឹងពេលខ្មែរក្រហមមកនៅហ្នឹងដើម្បីវ៉ៃទប់ទល់ជាមួយទាហានយួននិងទាហានខ្មែរខាងក្នុងហ្នឹង?

អ៊ុម ៖ ចាស ៗ

វណ្ណៈ ចឹងមីងមានដឹងថាមានស្បៀងយកមកពីណា?

អ៊ុម ៖ មិនដឹងជាគេយកមកពីណា គេចេះតែយកមកផ្ដល់ឲ្យយើងហូប កាលហ្នឹងមានរយៈមួយឆ្នាំដែរ ដែលហូបបបរហ្នឹង ដល់ក្រោយមកយើងបានបាយហូបធម្មតា ៗ

វណ្ណៈ ចឹងមេបញ្ជាការដូចលោកអៀង សារីគាត់មកកាន់កាប់តំបន់ហ្នឹងតាំងពីឆ្នាំណា ៧៩មកគាត់មកកាន់កាប់ហើយនៅ?

អ៊ុម ៖ គាត់មកនៅហ្នឹងតាំងពី៧៩ជាមួយតា ប៉ុល ពតអីហ្នឹង ៗ

វណ្ណៈ ចឹងមេបញ្ជាការតា អៀង សារី?

អ៊ុមៈ ចាស ៗ

វណ្ណៈ ចឹងតាអៀង សារីតា ប៉ុល ពតនៅហ្នឹងដែរ?

អ៊ុម ៖ នៅហ្នឹងដែរ តែក្រោយមកបានតា ប៉ុល ពតទៅនៅអន្លង់វែង ៗ

វណ្ណៈ ចឹង?

អ៊ុមៈ ចាស ៗ

វណ្ណៈ ចឹងតា ប៉ុល ពតដំបូងនៅម៉ាឡៃដែរ?

អ៊ុមៈ ចាស ៗ

វណ្ណៈ ចឹងគាត់មកនៅម៉ាឡៃជាមួយអៀង សារី?

អ៊ុម ៖ ចាស! ពេលនេះគាត់មិននៅទីតាំងហ្នឹងទេតែគាត់មកម្ដងនៅចំនួនមួយអាទិត្យ ពីរអាទិត្យចឹងទៅ ៗ

វណ្ណៈ ចឹងក្រោយមកប៉ុល ពតទៅនៅអន្លុងវែង?

អ៊ុមៈ ចាស ៗ

វណ្ណៈ ចឹងក្រោយមកឆ្នាំណា ប៉ុល ពតគាត់ទៅនៅអន្លង់វែងហ្នឹង?

អ៊ុម ៖ ខ្ញុំមិនសូវជាចាំឆ្នាំដែលហ្នឹង ដូចថាយើងមិនសូវជាចាប់អារម្មណ៍ គិតតែធ្វើការងារធ្វើម៉េចឲ្យមានជីវភាពធូរធារហ្នឹង ៗ

វណ្ណៈ ចឹងកាលមីងរត់មកចឹងមីងមិនទាន់មានគ្រួសារទេ?

អ៊ុម ៖ នៅ ៗ

វណ្ណៈ ចឹងមីងយកគ្រួសារនៅឆ្នាំណា?

អ៊ុម ៖ ខ្ញុំនៅពាក់កណ្ដាលឆ្នាំ៧៩ ខែ៦-៧ហ្នឹង ៗ

វណ្ណៈ ចឹងយកនៅឆ្នាំ៧៩ហ្នឹងដែរ?

អ៊ុម ៖ ចាស! តែខ្ញុំការនៅជំរំ គេសែនចំនួន៥គូរ ។

វណ្ណៈ ចឹងប្ដីមីងឈ្មោះអី?

អ៊ុម ៖ គាត់ឈ្មោះនួន សារឹម ។

វណ្ណៈ គាត់អតីតគាត់ជាទាហានខ្មែរក្រហមដែរ?

អ៊ុម ៖ ចាស ។

វណ្ណៈ ចឹងមីងមានកូនប៉ុន្មាននាក់?

អ៊ុម ៖ ខ្ញុំមានកូន៥នាក់ ។

វណ្ណៈ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

អ៊ុម ៖ ស្រីបីប្រុសពីរ តែគ្រួសារខ្ញុំស្លាប់តាំងពីឆ្នាំ៩៨ ។

វណ្ណៈ គាត់ស្លាប់ដោយសារអី?

អ៊ុម ៖ និរសាគាត់បាញ់អ្នកដែលចូលពីក្នុងមកគាត់ឃើញគេស្លូតក៏ឲ្យនៅជាមួយទៅដល់ដើរទៅមុនទៅ គេបាញ់ទៅ ។

វណ្ណៈ ចឹងប្ដីមីងធ្វើធំដែរ?

អ៊ុម ៖ ប្រធានកងវរៈសេនាតូច ។

វណ្ណៈ ចឹងយ៉ាងម៉េចបានជាស្គាល់គេហើយយកមកធ្វើជានិរសា?

អ៊ុម ៖ គាត់ទៅវៃគ្នានៅមុខចឹង ដូចថាគេចូលមកតាមក្រោយមកគាត់ឃើញគេដូចមានចិត្តអាណិតគេក៏យកមកនៅជាមួយបានមកនៅផ្ទះនេះបាន រយៈប្រហែលជា៦ខែដែរ បានវាសម្លាប់ថ្ងៃគាត់ស្លាប់ហ្នឹងពីរនាក់ គ្រួសារខ្ញុំមួយគ្រួសារគេមួយហើយគ្រួសារមួយទៀតនៅ....។

វណ្ណៈ ចឹងស្លាប់នៅឆ្នាំណា?

អ៊ុមៈ ស្លាប់នៅឆ្នាំ១៩៩៨ ។

វណ្ណៈ និរសាបាញ់?

អ៊ុមៈ ចាស ។

វណ្ណៈ ចឹងយ៉ាងម៉េចបានដឹងថានិរសាបាញ់?

អ៊ុម ៖ មុនដំបូងវាឲ្យគ្រួសារខ្ញុំចូលទៅរកត្រីក្នុងស្រះមួយចឹង ហើយគេនៅយាមខាងលើហើយមានម្នាក់ទៀតគេឈ្លៀសវៃគេមិនឲ្យគាត់ចុះទេ ឲ្យអានិរសាហ្នឹងទៅរកត្រីគាត់នៅធ្វើដងវែកខាងលើ ។

វណ្ណៈ បាទ ។

អ៊ុម ៖ នៅក្នុងពេលហ្នឹងមិនអាចធ្វើអីយើងកើតទេ គាត់អង្គុយធ្វើដងវែកហ្នឹងទៅដល់ពេលយើងរកត្រីបានយើងមិនដើរទៅកន្លែងវិញ ។

វណ្ណៈ  បាទ ។

អ៊ុម ៖ ពេលដើរទៅវាដើរពីក្រោយ  ប្ដីខ្ញុំដើរបន្ទាប់វាហើយមួយទៀតដើរពីមុនដល់ហើយវាបាញ់រះទៅម៉ាត្ដួខ្លួនគាត់ហ្នឹង១៩គ្រាប់ ។

វណ្ណៈ  ចឹងម្នាក់ទៀតក៏ងាប់ដែរ?

អ៊ុម ៖ ស្លាប់ទាំងពីរ  គេ៩គ្រាប់ប្ដីខ្ញុំ១៩គ្រាប់ ។

វណ្ណៈ  ចឹងនិរសាហ្នឹងជាខ្មែរក្រហមដែរ?

អ៊ុម ៖ អត់ទេ  ជាអ្នកមកពីក្នុងដូចថាគេបញ្ជាពីនោះមកធ្វើម៉េចឲ្យសម្លាប់កម្មាភិបាលខ្មែរក្រហមហ្នឹងបានគេឲ្យយើងឡើងស័ក្ដ ។

វណ្ណៈ  ចឹងកាលដែលចូលមកហ្នឹងយើងមិនដឹងថាមនុស្សចម្លែកមកពីខាងណាទេ?

អ៊ុម ៖ ចឹង  តែមេបញ្ជាការបានប្រាប់គាត់ដែរ  តែគាត់មានចិត្តអាណិតគេ  គាត់យកគេនៅជាមួយ ។

វណ្ណៈ  ចឹងនិរសាហ្នឹងឈ្មោះអីទៅ?

អ៊ុម ៖ ឈ្មោះ  អាអៀត  តែដល់ក្រោយមកវាងាប់ដែរ  ឮថាវាបាញ់គេងាប់ច្រើនដែរ  ហើយមានឈ្មោះខ្មៃមួយទៀត ។

វណ្ណៈ  ចឹងកាលហ្នឹងគេឲ្យមកតាមរបៀបណាខ្ញុំដូចជាឆ្ងល់ដែរ  ព្រោះខ្មែរក្រហមតឹងរឹងណាស់?

អ៊ុម ៖ ចាស!  នៅពេលដែលកំពង់តែវៃគ្នាចឹងវាអត់មានចូលមកពីមុខទេ  វាលួចចូលពីក្រោយឆ្នាំងបាយយើងឯណោះវាមកអង្គុយកន្ទែងយើងនៅហ្នឹង  បើពាក្យខ្មែរក្រហមវាមកអង្គុយនៅឆ្នាំងបាយ  ហើយយើងមកពីវៃគ្នាវិញឃើញវានៅអង្គុយហ្នឹង ។

វណ្ណៈ  ចឹងកាលហ្នឹងហេតុអីបានជាទាហានខាងខ្មែរក្រហមមិនចាប់មិនបាញ់?

អ៊ុម ៖ ចឹងបានជាខ្ញុំថាហ្នឹង  គាត់ហ្នឹងមានចិត្តអាណិត ។

វណ្ណៈ  ចឹង?

អ៊ុម ៖ ចាស ។

វណ្ណៈ  ចឹងគេស្លៀកពាក់ជាទាហានយ៉ាងម៉េច?

អ៊ុម ៖ ស្លៀកពាក់ជាទាហានមកពីខាងក្នុងធម្មតា  ដល់ហើយគេសុំយើងចុះចូលថាគេវៃចាញ់ចឹងទៅគេសុំចុះចូលមកនៅជាមួយបំរើការងារចឹងទៅ ។

វណ្ណៈ  ចឹងគេនិយាយថាសុំខាងខ្មែរក្រហមនៅជាមួយព្រោះនៅខាងនោះគេធ្វើបាប?

អ៊ុម ៖ ចាស!គេចេះនិយាយធ្វើម៉េចឲ្យយើងទន់ចិត្ត ។

វណ្ណៈ  ចឹងនៅពេលបាញ់ហើយរត់បាត់តែម្ដង?

អ៊ុម ៖ រត់ទៅវិញទៅ ។

វណ្ណៈ ចឹងម៉េចបានដឹង?

អ៊ឹម ៖ កុំអីមិនចាប់ភ័ស្តុតាងបានដែរ វាជ្រុះក្រមាហើយវាជ្រុះអាវដាយកកាំភ្លើងខ្ញីគ្រួសារខ្ញុំទៅ ដល់ហើយកាំភ្លើងខ្ញីហ្នឹងវាជ្រុះបង់វាយកបានតែកាំភ្លើងទៅ ហើយគេអូរហ្នឹងវាបាក់ដងអីហ្នឹងចុះវារត់ប្រដាត់ប្រគីងនោះក្នុងព្រៃវាលស្រែហ្នឹងកុំអីមិនថាវាដែរ ហើយអ្នកទៅបេះអំពិលហ្នឹងមកវិញវាបាត់ពីរនាក់ហ្នឹងវា ឃើញតែក្រមាជ្រុះហើយមិនឃើញវាហ្នឹង ដល់ហើយសន្និដ្ឋានថាវាហ្នឹងទៅ ។

វណ្ណៈ បាទ ។

អ៊ឹមៈ ដល់ក្រោយមកវារត់ទៅនោះបាត់ ។

វណ្ណៈ ចឹងខ្ញុំចង់និយាយបកទៅសកម្មភាព៧៩វិញ?

អ៊ឹមៈ ចាស ។

វណ្ណៈ ចឹងមីងមកនៅទីនេះកាល៧៩ហ្នឹង ថាសុទ្ធតែព្រៃអត់មានផ្ទះសំបែងទេ?

អ៊ឹមៈ ចាស!អត់មានទេ ។

វណ្ណៈ ចឹងកំលាំងខ្មែរក្រហមហ្នឹងចេះតែរស់នៅក្នុងព្រៃហ្នឹងរហូតទៅ?

អ៊ឹមៈ ចាស ។

វណ្ណៈ ចឹងកាលហ្នឹងមានខ្មែរក្រហមខ្លះដូចថាយើងរត់មកពីខាងក្នុងចឹងរត់ទៅថៃចេញពីថៃទៅស្រុកក្រៅអីមានទេ?

អ៊ឹមៈ មាន ខ្ញុំកាលហ្នឹងគេហៅទៅដែលតើតែខ្ញុំដូចថាសើច...ឯងខ្លាចបែកម៉ែបែកឪចឹងទៅខ្លាចម៉ែឪមករកមិនឃើញអត់ទៅវិញឡានគេមកយកតើដូចថាក្រយៅវាកប់ណាស់ កាលពីដើមយើងអត់គិតចឹងទេ គិតខ្លាចម៉ែឪ ។

វណ្ណៈ ចឹងជំនាន់ខ្មែរក្រហមអីមីងមានដែលបានទៅលេងផ្ទះដែរ?

អ៊ឹមៈ អត់ ។

វណ្ណៈ ចឹងរត់មកនេះហើយបែកម៉ែឪទៀត មិនចង់រត់តទៅទៀតទេ?

អ៊ឹមៈ ចាស ។

វណ្ណៈ ចង់តែទៅផ្ទះ?

អ៊ឹមៈ ចង់តែទៅផ្ទះដែលតែធ្វើម៉េចបានទៅ ។

វណ្ណៈ ចឹងនិយាយថាកំលាំងខ្មែរក្រហមដែលវៃជាមួយទាហានរដ្ឋាភិបាលហ្នឹង មីងមិនដឹងថាសម្ភារគេយកមកពីខាងណាទេ គេយកមកឲ្យប្រើ?

អ៊ឹមៈ ចាស ។

វណ្ណៈ ដូចជាការក្អែងដូចជាការហូបចុកអីហ្នឹងអត់ដឹងទេ?

អ៊ីមៈ ចាស!គេហៅឲ្យទៅបើកចេះតែទៅៗ ។

វណ្ណៈ ចឹងកាលហ្នឹងមីងមីនណាស់ដូចថាមីននៅម៉ាខ្សែនេះ ដូចចំការមីនចឹងតាមដីង?

អ៊ីមៈ ចាស ។

វណ្ណៈ ដូចថាសុទ្ធតែចំការមីនទេ?

អ៊ីម ៖ ចាស!នេះពួកខ្ញុំដែលយួនវ៉ៃមករត់នៅឆ្នាំ១៩៨៥ ៨៤-៨៥ហ្នឹងគេវ៉ៃមកមួយសារមកពួកខ្ញុំរត់ឆ្លងទៅដីថៃ ។

វណ្ណៈ បាទ ។

អ៊ីម ៖ ទៅនៅជាមួយថៃដូចថាមានជំរំមួយចឹងទៅ ។

វណ្ណៈ បាទ ។

អ៊ីមៈ យើងទៅរស់នៅជាមួយគេហ្នឹងទៅចេះតែនៅៗទៅយើងនៅទៅដូចថាថា វាលំបាកពេកយើងរត់ទៅនៅខាងភ្នំខៀវ ។

វណ្ណៈ បាទ ។

អ៊ីម ៖ ទៅភ្នំខៀវនិយាយពីមនុស្សងាប់គរដើងគ្នា ។

វណ្ណៈ ងាប់ដោយសារអី?

អ៊ីម ៖ គ្រុនចាញ់ឡើងភ្នំចុះភ្នំ ។

វណ្ណៈ អាហ្នឹងឆ្នាំណាមីង?

អ៊ីម ៖ ឆ្នាំ៨៥ ។

វណ្ណៈ ខាងខ្មែរក្រហមស្លាប់?

អ៊ីម ៖ ចាស ។

វណ្ណៈ ភ្នំខៀវនៅខេត្តណា?

អ៊ីម ៖ ភ្នំខៀវនៅខាងប៉ៃលិន ។

វណ្ណៈ គ្រុនចាញ់ខ្លាំងណាស់ខាងប៉ៃលិនខាងភ្នំយ៉ាតអី?

អ៊ីមៈ ចាស ។

វណ្ណៈ ទាហានយួនក៏ងាប់ច្រើនដែរ?

អ៊ីម ៖ ចាស!គ្រួសារខ្ញុំឈឺជិតស្លាប់កាលហ្នឹងឯង ។

វណ្ណៈ បាទ ។

អ៊ីមៈ ដល់ហើយអន្តរាគមហ្នឹងកាលហ្នឹងអ៊ំគាត់ឃើញឈឺច្រើនពេកឲ្យមកនៅជំរំ ។

វណ្ណៈ  អីហ្នឹងមានន័យថាអី ប៉ុល ពត?

អ៊ុមៈ  ចាស!អីខៀវ សំផន ។

វណ្ណៈ  អីខៀវ សំផនអីហ្នឹង?

អ៊ុមៈ  ចាស!គាត់ឃើញឈឺពេកគាត់ឲ្យផ្លាស់ពីហ្នឹងឡើងឡានពីហ្នឹងមកនៅជំរំ៨៩វិញជំរំថៃហ្នឹង ។

វណ្ណៈ  នៅជំរំនៅពេលដែលវៃជាមួយយួនជាមួយទ័ពខាងខ្មែរខាងក្នុងហ្នឹង?

អ៊ុមៈ  ចាស ។

វណ្ណៈ  ចឹងកាលហ្នឹងតា ប៉ុល ពត តា ខៀវ សំផន តា អៀង សារីមានមកសួរសុខទុក្ខកងទ័ពខ្មែរក្រហមដែរ?

អ៊ុម ៈ  មកសួរសុខទុក្ខមកបង្រៀនចឹងទៅ ។

វណ្ណៈ  មកបង្រៀនខាងអីខ្លះ?

អ៊ុម ៈ  បង្រៀនឲ្យដូចថាឲ្យយើងខំតស៊ូដើម្បីយកទឹកដីមកវិញចឹង ។

វណ្ណៈ  ចឹងគាត់មកបង្រៀនកងទ័ព?

អ៊ុមៈ  ចាស!ឲ្យយើងចេះតស៊ូយកទឹកដីមកវិញ ។

វណ្ណៈ  យកទឹកដីពីណាពីយួនវិញអីចឹង?

អ៊ុមៈ  ចាស!កុំឲ្យបាត់បង់ ។

វណ្ណៈ  ចឹងមកប្រជុំនិយាយចឹងដើម្បីឲ្យយើងមានទឹកចិត្តដើម្បីវៃ?

អ៊ុម ៈ  ចាស ។

វណ្ណៈ  ចឹងមីនមានច្រើនណាស់ចឹងមីងគិតថាខាងរដ្ឋាភិបាលឬមីនពីណាជាអ្នកដាក់?

អ៊ុម ៈ  ដាក់ទាំងអស់គ្នា ទាំងសងខាង តែខាងឯណោះគេច្រើនមីនប៉ុនៗនេះ គេហៅមីនស្នាច់ ផ្ទុះស្លាប់អស់ច្រើនដែលមកនៅព្រំដែនហ្នឹង ។

វណ្ណៈ  ចឹងមានន័យថាដាក់ទាំងខាងក្នុងទាំងខាងក្រៅ?

អ៊ុមៈ  ចាស ។

វណ្ណៈ  ចឹងពេលដាក់ហើយនាំគ្នាដើរចោលអស់?

អ៊ុម ៈ  ដាក់ហើយពេលយួនវៃចូលមកខ្លាំងនាំគ្នាទៅនៅនោះមួយរយៈ៥ទៅ៦ឆ្នាំបានយើងទើបត្រឡប់ចូលមកវិញ ។

វណ្ណៈ  បាទ ។

អ៊ុម ៈ  ពេលត្រឡប់មកវិញនាំគ្នាឈូសផ្លូវធំៗដើរ ហើយប្រពន្ធកូនអីមិនហ៊ានឲ្យដើរផ្ដេះផ្ដាសទេ ទំរាំបានដីប៉ុណ្ណឹងគ្រោះថ្នាក់មិនស្មើរទេ ស្លាប់អស់មិនតិចទេ ។

វណ្ណៈ ចឹងនៅដុំហ្នឹងមិនទាន់អស់មីនទេ?

អ៊ីម ៖ អត់ទេ ឥឡូវស៊ីម៉ាក់មកការអស់ហើយ ។

វណ្ណៈ ចឹងតាំងពី៧៩មក៨១-៨២-៨៣-៨៤អីមីងនៅហ្នឹងទេ?

អ៊ីម ៖ ចាស ។

វណ្ណៈ ចឹងនៅចល័តខាងម៉ាឡៃហ្នឹង?

អ៊ីមៈ ចាស ។

វណ្ណៈ បើតាមមីងដឹងមានទ័ពខ្មែរក្រហមប្រហែលជារាប់ម៉ឺននាក់ដែរ?

អ៊ីម ៖ មិនមានប៉ុន្មានទេ ។

វណ្ណៈ ចឹងអត់មានច្រើនទេ?

អ៊ីម ៖ ចាស!ក្នុងមួយអង្គភាពចឹងទៅ ដូចថាមួយវរៈសេនាតូចចឹងមានគ្នាប្រហែលជា៥០ទៅ៦០នាក់ ចឹងទៅ ។

វណ្ណៈ អត់មានច្រើនទេ?

អ៊ីមៈ អត់មានច្រើនប៉ុន្មានទេ ។

វណ្ណៈ តែនៅតែវៃទប់ទល់បាន?

អ៊ីម ៖ ចាស! មួយវរៈសេនាធំចឹងទៅមានប្រហែលជា១០០ជាងចឹងទៅ ។

វណ្ណៈ បាទ ។

អ៊ីម ៖ តាមមួយអង្គភាពចឹងទៅ មាន១០៦-១០៧-១០៨និង១០៩ទ័ពគេអង្គភាពគេហៅចឹង ។

វណ្ណៈ ចឹងកងទ័ពខ្មែរក្រហមមានតាំងពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៩៦?

អ៊ីម ៖ ចាស ។

វណ្ណៈ ចឹងកងទ័ពខ្មែរក្រហមមានប៉ុន្មានគេហៅកងអីគេខ្លះ?

អ៊ីមៈ គេហៅ១០៦-១០៧ចឹងទៅ ។

វណ្ណៈ ចឹង១០៦ដល់?

អ៊ីមៈ ១០៦-១០៧-១០៨-១០៩ ។

វណ្ណៈ ចឹងដល់១០៩?

អ៊ីមៈ ចាស ។

វណ្ណៈ ចឹងកាលហ្នឹងមេបញ្ជាការកងទ័ពពីណាគេ?

អ៊ីម ៖ មានអ៊ីភាព ។

វណ្ណៈ គាត់ឈ្មោះអ៊ីភាព?

អ៊ុម ៖ សុខ ភាព "អ្នកនៅជិតនិយាយថាមានតា ហុងទៀត" ។

វណ្ណៈ ចឹងគាត់ជាមេបញ្ជាការទ័ពរបស់តាអៀង សារី?

អ៊ុមៈ ចាស! មានតា ហុងមានគាត់ ។

វណ្ណៈ តា ហុងហ្នឹងពីណាគេ?

អ៊ុមៈ មិនដឹងជាជីតាគាត់ឈ្មោះអីផង ខ្ញុំមិនសូវស្គាល់ដែរ ។

វណ្ណៈ ចឹងតា ហុងសព្វថ្ងៃនៅនេះដែរ?

អ៊ុម ៖ គាត់នៅនេះឯង ។

វណ្ណៈ ចឹងតាហុងនេះទីនេះដែរ?

អ៊ុម ៖ ចាស! តែស្រុកកំណើតគាត់នៅកំពង់ចាម ។

វណ្ណៈ តែឥឡូវគាត់ធ្វើអីដែរ?

អ៊ុម ៖ មិនដឹងជាគាត់ធ្វើអីទេ ខ្ញុំមិនសូវបានដើរ វវល់តែគេសួរខ្ញុំថាយ៉ាងម៉េចបានសួរមិនចេះស្គាល់ សោះបើខ្ញុំមិនដែលដើរ ។

វណ្ណៈ ចឹងតា ហុងនិង តា សុខ ភាពអីមានតួនាទីប្រហែលគ្នា?

អ៊ុមៈ ចាស ។

វណ្ណៈ តែសុខ ភាពគាត់នៅមានមុខមាត់?

អ៊ុមៈ គាត់នៅធ្វើការដល់រាល់ថ្ងៃ ។

វណ្ណៈ ចឹងតា ហុងគាត់ឈប់ឬយ៉ាងម៉េច?

អ៊ុមៈ មិនដឹងជាយ៉ាងម៉េច ។

វណ្ណៈ ចឹងកាលឆ្នាំ៨១-៨២-៨៣មកដល់ឆ្នាំណាបានគេថាមានកងរំដោះជាតិគេហៅទៀមទារមានកង ច្រើននោះ?

អ៊ុមៈ កាលសម្រុះសម្រួលគ្នាហ្នឹង ។

វណ្ណៈ មិនទាន់សម្រុះសម្រួលគ្នាទេ នៅវៃជាមួយខាងក្នុងនៅឡើយទេ ។

អ៊ុមៈ ចាស ។

វណ្ណៈ តែមានទ័ពម៉ូលីណាការទ័ពស្អីហ្នឹងទ័ពហ្នឹងកើតនៅឆ្នាំណា?

អ៊ុម ៖ ដូចជាអត់មានទេនៅទីនេះអត់មានទេ ។

វណ្ណៈ ចឹងនៅម៉ាឡៃនេះអត់មានទេ?

អ៊ុមៈ ចាស ។

វណ្ណៈ ចឹងទ័ពសេរីការហ្នឹងអត់មានទេ?

អុីមៈ អត់មានទេ ។

វណ្ណៈ ចឹងនៅតំបន់នេះសុទ្ធតែខ្មែរក្រហមសុទ្ធ?

អុីមៈ សុទ្ធតែខ្មែរក្រហម ។

វណ្ណៈ ចឹងមីងនៅជាបន់ដៃនៅនេះរហូតដល់ឆ្នាំណាបានមីងទៅលេងស្រុកកំណើត?

អុីម ៈ ខ្ញុំឆ្នាំ២០០០ជាងបានទៅលេងស្រុកបានម្តង ទៅម្តងមិនបានស្គាល់គេឯងទេ ចាំតែឈ្មោះតែមិនស្គាល់មនុស្សគេរត់អោបចឹងមិនដឹងថាឈ្មោះអីៗ ឈ្មោះអីដល់គេទៅបាត់ចឹងទៅបានសួរគេ គេថាហ្នឹងឯងមកអោបឯង កាលនោះខ្ញុំនៅផ្ទះកាលខ្ញុំមកខ្ញុំស្គមហ្នឹង ។

វណ្ណៈ បាទ ។

អុីមៈ ហើយខ្ញុំមកនៅនេះទៅដូចថាធាត់ចឹងទៅ ។

វណ្ណៈ ចឹងមីងគិតថាជំនាន់ខ្មែរក្រហមការដឹងនាំយ៉ាងម៉េចដែរ ពួកគាត់ដឹកនាំកាលសម័យហ្នឹង បើតាមគំនិតរបស់មីង?

អុីម ៈ នេះតាមដែលខ្ញុំបានរស់នៅជាមួយគាត់ គាត់មិនឲ្យយើងរស់នៅសេរី ប្រើអំពើហឹង្សាក្នុងក្រុមគ្រួសារដូចថាគាត់ចង់ឲ្យយើងធ្វើការឲ្យមានចំណេញកុំឲ្យខាតហើយ កុំឲ្យយើងឈ្លួសទាស់គ្នានៅក្នុងអង្គភាពហ្នឹង ។

វណ្ណៈ បាទ ។

អុីម ៈ គាត់នែនាំយើងឲ្យល្អទាំងអស់ ខ្ញុំអត់មាននិយាយអួតទេ ។

វណ្ណៈ ត្រូវមីងនិយាយអ្វីដែលមីងឃើញបានជួបប្រទះ ។

អុីម ៈ ចាស ។

វណ្ណៈ ហើយអ្នកផ្សេងជួនប្រទះយ៉ាងម៉េចអាហ្នឹងជារឿងរបស់គេ?

អុីម ៈ ចាស!ដូចថារស់នៅសព្វថ្ងៃជាមួយខ្មែរក្រហមមិនទាន់ប្របូកប្របល់ពីក្នុងមកក្រៅពីក្រោមកក្នុងអីហ្នឹង ។

វណ្ណៈ ចឹងមីងចង់និយាយរយៈពេលណាតាំងពី៧៩?

អុីម ៈ តាំងពី៧៩រហូតដល់រយៈខ្មែរក្រហមនៅហ្នឹង ។

វណ្ណៈ ផ្តាច់ខ្លួន?

អុីម ៈ ចាស!ចង់កង់ម៉ូតូដាក់នៅហ្នឹងគ្មានបាត់គ្មានអីទេ ធ្វើចំការពោតដាក់ពេញជង្រុកក៏មិនដែលបាត់ដែរ អត់មានចោរអត់មានអីទេ ។

វណ្ណៈ ចឹងកាល៧៩ដល់៩៦ការគ្រប់គ្រងល្អ?

អុីម ៈ ចាស ។

វណ្ណៈ  អត់មានបាត់របស់ទ្រព្យទេ?

អ៊ុម  :  អត់ ។

វណ្ណៈ  ហើយយ៉ាងម៉េចទៀតមីង?

អ៊ុម  :  ដល់ពេលចឹងទៅយើងមិត្តភាពជាមួយថៃហ្នឹងមិនមានប្រេះឆាគ្នាទេ  នៅសាមគ្គីគ្នាជាប់  យើងចង់ដើរទៅពីរនាក់ម្នាក់ឯងក៏អត់មានធ្វើអីយើងដែរ ដល់មកដល់សម័យបច្ចុប្បន្ននេះយ៉ាប់ ។

វណ្ណៈ  យ៉ាប់យ៉ាងម៉េចមីង?

អ៊ុម  :  យ៉ាប់ដូចថាមានចោរទៅលួចស្អីៗគេចឹង   ម៉ាស៊ីនគេដាក់បូមទឹកដាក់ដំណាំទៅលួចមកម៉ូតូទៅឡានទៅ ដូចថាវាមិនល្អដូចសម័យខ្មែរក្រហម ។

វណ្ណៈ  ចឹងមានចូលទៅលួចនៅដីថៃទៀត?

អ៊ុម  :  ចាស! ហើយខ្ញុំសព្វថ្ងៃហ្នឹងមិនដែលហ៊ានទៅទេ ។

វណ្ណៈ  លួចម៉ាស៊ីនបូមទឹកថៃ?

អ៊ុម  :  ចាស! និយាយរួមឲ្យតែឃើញអីលួចហ្នឹង    ឲ្យតែវាឃើញតាំងពីច្របូកច្របល់ចេញចូលពីក្នុងមកនៅជាមួយខ្មែរក្រហមហ្នឹង ។

វណ្ណៈ  ចឹងម៉ូតូដាក់ក្នុងចំការអីឲ្យតែឃើញលួច?

អ៊ុម  :  លួចទាំងអស់  ចឹងបានថៃថានៅជាមួយខ្មែរក្រហមស្រួលអត់ដែលមានបាត់របស់របរអី ។

វណ្ណៈ  ចឹងកាលនៅក្នុងជំរំនេះកងទ័ពអីដាំបាយរួមយ៉ាងម៉េចទៅ?

អ៊ុម  :  ដាំបាយតាមក្រុមៗ ។

វណ្ណៈ  ចឹងមានម្ហូបអាហារទៅហូបធម្មតាទៅ?

អ៊ុមៈ   ចាស ។

វណ្ណៈ  ចឹងមានដើរចាប់បានទាហានមកពីខាងក្នុងទេ?

អ៊ុម  :  មានចាប់បានគេយកទៅដាក់នៅកន្លែងឃុំឃាំងទៅ ។

វណ្ណៈ  ចឹងមានកន្លែងឃុំឃាំងទៀត?

អ៊ុម  :  ចាស ។

វណ្ណៈ  គេមានសម្លាប់ទេ?

អ៊ុម  :  អត់មានសម្លាប់ទេ  គេឲ្យបាយទឹកធម្មតា ។

វណ្ណៈ  ឃុំឃាំងហើយគេ?

អ៊ុម  :  បើយើងកែប្រែគេឲ្យនៅជាមួយ  មានអ្នកនៅជាមួយរហូតដល់សព្វថ្ងៃ ។

វណ្ណៈ  ពីណាគេមានឈ្មោះអី?

អ៊ីម ៖ មើលមានឈ្មោះខុម ឈ្មោះធឿន ចាន់ថាមកស្លាប់ហើយនៅតែប្រពន្ធរស់នៅហ្នឹងនិងពូរីមួយទៀត ។

វណ្ណៈ ចឹងរាល់ថ្ងៃគាត់នៅរស់ទេ?

អ៊ីម ៖ ចាស ។

វណ្ណៈ ចឹងហ្នឹងអតីតទាហាន?

អ៊ីម ៖ ទាហានខាងក្នុង មាននៅច្រើនតែខ្ញុំមិនសូវស្គាល់គេ ។

វណ្ណៈ ខ្មែរក្រហមចាប់បានចូលតស៊ូជាមួយគ្នា?

អ៊ីមៈ ចាស ។

វណ្ណៈ ចឹងមាននៅរស់ដល់សព្វថ្ងៃ?

អ៊ីមៈ ចាស ។

វណ្ណៈ ចឹងមីងមានច្រើនទៀតទេ?

អ៊ីមៈ ចាស!មានច្រើនដែលនៅរស់សព្វថ្ងៃ ។

វណ្ណៈ ហ្នឹងសុទ្ធតែទាហានខាងក្នុងដែលចូលមក?

អ៊ីមៈ ចាស!ដែលគេសុំចុះចូលមក ។

វណ្ណៈ ចឹងមីងមានបានដឹងទេថា ទាហានខាងក្នុងចាប់បានទាហានខ្មែរក្រហមមានដែលឃើញដោះលែងមកវិញទេ?

អ៊ីម ៖ មិនដែលឃើញ ទំរាំដោះលែងមកក៏យូរវ៉ៃតប់គ្នាចង់ងាប់ចង់រស់ ។

វណ្ណៈ ចឹងមីងថាមិនងាយលែងទេ?

អ៊ីមៈ ចាស ។

វណ្ណៈ ចឹងខ្ញុំចង់សួរបកទៅវិញកាលសម័យឆ្នាំ៧៥មីងមកខាងកាត់ដេរហ្នឹងហើយនៅឬមួយនៅតាមភូមិនៅឡើយទេ?

អ៊ីម ៖ ដើមឆ្នាំ៧៥ខ្ញុំនៅតាមភូមិនៅឡើយទេនៅលើកទំនប់ ។

វណ្ណៈ ចឹងនៅលើកទំនប់ប្រឡាយនៅក្នុងភូមិជាមួយឪពុកម្ដាយ?

អ៊ីមៈ ចាស! កាលឆ្នាំ៧៤ហ្នឹងចូលជាកងនារីសេនាជនភូមិ ។

វណ្ណៈ ចឹងកាលហ្នឹងមីងចូលបដិវត្តន៍តាំងពីឆ្នាំ៧៤ជានារីសេនាជនមែនទេ?

អ៊ីម ៖ ចាស ។

វណ្ណៈ ចឹងសេនាជនមានស្រីដែរ?

អ៊ីមៈ មាន ។

វណ្ណៈ ជាសេនាជនភូមិ?

អ៊ីមៈ ចាស ។

វណ្ណៈ ចឹងក្រោយមកទៀតនៅពេលដែលខ្មែរក្រហមឈ្នះ ឈ្នះឆ្នាំ៧៥?

អ៊ីម ៈ ពេលខ្មែរក្រហមវ៉ៃភ្នំពេញបាននៅឆ្នាំ៧៥ខែ៤ចឹង ។

វណ្ណៈ ខែ៤ ។

អ៊ីមៈ ខែខែមេសា ។

វណ្ណៈ បាទ ។

អ៊ីមៈ គេបានរើសនារីមកភ្នំពេញហ្នឹងខ្ញុំចេញពី ផ្ទះមកភ្នំពេញបណ្តោយ ។

វណ្ណៈ ចឹងពេលមកដល់ភ្នំពេញនៅខាងអី?

អ៊ីម ៈ ខ្ញុំនៅខាងតម្បាញ មិនមែននៅខាងកាត់ដេរទេ ។

វណ្ណៈ ចឹងនៅខាងតម្បាញពីឆ្នាំ១៩៧៥-៧៩?

អ៊ីម ៈ ចាស ។

វណ្ណៈ ចឹងខាងហ្នឹងប្រធានតម្បាញពីណាគេ?

អ៊ីម ៈ បងសារ៉ន ។

វណ្ណៈ ស្រី?

អ៊ីមៈ ប្រុស គណៈរោងចក្រហ្នឹង ។

វណ្ណៈ គណៈរោងចក្រតម្បាញ?

អ៊ីមៈ ចាស ។

វណ្ណៈ ចឹងមានស្គាល់តាប្រធានធំនោះមានស្គាល់ទេ?

អ៊ីម ៈ មានតា ចេង អន ។

វណ្ណៈ ចឹងតា ចេង អនគាត់នៅកាន់ខាងតម្បាញ?

អ៊ីម ៈ ចាស!គាត់កាន់កាប់ពីមុនគេហៅឧស្សាហ៍កម្ម ។

វណ្ណៈ ចឹងតាចេង អនគេចាប់គាត់កាលសម័យហ្នឹង?

អ៊ីម ៈ គេចាប់គាត់ពីសម័យឆ្នាំ៧៦-៧៧ហ្នឹង គេចាប់គាត់ ។

វណ្ណៈ ចឹងម៉េចមីងបានដឹងថាគេចាប់ខ្លួនគាត់?

អ៊ីម ៈ កាលហ្នឹងគេថាជាប់និន្នាការខ្ញុំមិនសូវដឹងរឿងគេដែរ ។

វណ្ណៈ បាទ ។

អ៊ីម ៈ ក្រោយមកទៀតគេផ្លាស់បងសារ៉នហ្នឹងទៅកាលគាត់នៅធូរ ដល់ផ្លាស់ពីបងសារ៉នហ្នឹងមកបងភន

ស្រីមួយទៀតគឺធ្វើលំបាកក្នុងការហូបចុក ។

វណ្ណៈ  ចឹងផ្លាស់សារ៉ន?

អ៊ុមៈ  ចូលបងភនមកពីខាងខេត្តតាកែវ ។

វណ្ណៈ  ចឹងឈ្មោះភនហ្នឹងឆ្នាំណាគាត់មក?

អ៊ុម ៈ  ឆ្នាំ៧៨ គាត់មកបានតែមួយឆ្នាំ ។

វណ្ណ  ចឹងការហូបចុកលំបាកតែម្តង?

អ៊ុមៈ  ការហូបចុកលំបាក ។

វណ្ណៈ  ចឹងកាលហ្នឹងកងនារីនិងកងយុវជនគេនៅផ្សេងពីគ្នា?

អ៊ុម ៈ  នៅផ្នែកខុសគ្នា ដូចថាមួយរោងចក្រហ្នឹងមានគ្នា៦០០នាក់ជាង ខាងស្រីៗនៅតាមវេរៈគេចឹងទៅ ខាងប្រុសៗគេនៅខាងជួសជុលម៉ាស៊ីនចឹងទៅវេរៈគេផ្សេងទៅ ។

វណ្ណៈ  បាទ ។

អ៊ុម ៈ  គេនៅផ្នែកខុសគ្នា ។

វណ្ណៈ  ចឹងនៅកងតម្បាញហ្នឹងមានគ្នាប៉ុន្មាននាក់?

អ៊ុម ៈ  មាន៦៤០នាក់ ។

វណ្ណៈ  ចឹងមីងគិតថាគ្នាជាង៦០០នាក់ហ្នឹងមីងមានដឹងថាមានគេចាប់ខ្លួនឬមានបាត់ខ្លួនឬគេផ្លាស់យកទៅខាងណាមានទេ?

អ៊ុម ៈ  មានកាលឆ្នាំ៧៧ហ្នឹង ខ្ញុំប៉ិសទៅជាមួយគេដែលហ្នឹង ។

វណ្ណៈ  ចឹងមីងប៉ិសគេចាប់ខ្លួនដែរ?

អ៊ុមៈ  ចាស ។

វណ្ណៈ  ចឹងកាលហ្នឹងមីងមិនមែននៅខាងនិរតីទេ?

អ៊ុម ៈ  អត់ទេ បងភននោះបានខាងនិរតី ខ្ញុំនៅខាងបូព៌ា ។

វណ្ណៈ  ចឹងកាលហ្នឹងចាប់សោភីមទៅគេស្រាវជ្រាវច្រើន?

អ៊ុម ៈ  ចាស!ដល់ខ្ញុំគេស្រាវជ្រាវមកដឹងថាខ្ញុំគ្មានជាប់និន្នាការជាមួយសោភីមអី ចឹងកាលហ្នឹងខ្ញុំចេញពីផ្ទះមកដល់រោងចក្រតែម្តង ។

វណ្ណៈ  បាទ ។

អ៊ុម ៈ  ចឹងកាលហ្នឹងខ្ញុំចេញពីផ្ទះមក មកដល់រោងចក្រតែម្តង ។

វណ្ណៈ  ចឹងមីងគិតមើលថា ខ្មែរក្រហមធ្វើហ្នឹងត្រឹមត្រូវអត់ ដូចថាចាប់មេហើយដូចថា កូនចៅយើងមិនធ្វើតាមមេមែនទេ?

អ៊ីមៈ  ចាស ។

វណ្ណៈ  ដូចថាគេចោទថាមេក្បត់ដូចលោកឹមអី  កូនចៅហ្នឹងគ្នាមិនបានដឹងអីសោះហើយគេចាប់ទៅដាក់គុក ឬមួយសម្លាប់បាត់ចឹងតើមីងគិតថាការដឹកនាំហ្នឹងល្អឬមិនល្អទេសម្រាប់មីង  យើងនិយាយអ្វីដែល ការឃើញពិតនោះណាស់?

អ៊ីម  :  ខ្ញុំគិតថាធ្វើចឹងអត់ត្រឹមត្រូវទេ    ព្រោះអីអ្នកដែលនៅអង្គភាពជាមួយគ្នាមែន    តែធ្វើតែក្រោម បញ្ជាគេទាំងអស់ ។

វណ្ណៈ  ចឹងមានចំនុចអាក្រក់ខ្លះខ្មែរក្រហម?

អ៊ីម  :  ចាស ។

វណ្ណៈ  ចឹងមីងគិតថាមេដឹកនាំហ្នឹងគ្មានការយកចិត្តទុកដាក់ឬមានការធ្វេសប្រហែស?

អ៊ីម  :  ចាស!  តាមគាត់ចង់ធ្វើឲ្យល្អ  តែអ្នកនៅក្រោមៗគាត់ចេះតែក្រឡៃទៅណាស់ ។

វណ្ណៈ  ដូចជាចាប់មេចាប់ដល់កូន?

អ៊ីម  :  ចាស ។

វណ្ណៈ  ចឹងមីងគិតថា  បើថ្នាក់លើមិនមានបញ្ជាមកទេថ្នាក់ក្រោមអាចធ្វើបានទេការងារហ្នឹង?

អ៊ីម  :  អត់!តែថ្នាក់លើប្រាប់ថាធ្វើឲ្យល្មមសមរម្យទៅ  តែថ្នាក់ក្រោមយកមកធ្វើឲ្យសើសបន្តិចទៀតទៅ កាលហ្នឹងវៃអ្នកចេះអស់ទៅ  នៅអ្នកល្ងង់គេឲ្យធ្វើប៉ុននេះ  បែរជាទៅធ្វើប៉ុននោះ ។

វណ្ណៈ  ចឹងមីងគិតថាថ្នាក់ក្រោមធ្វើលើស?

អ៊ីម  :  ចាស ។

វណ្ណៈ  ចឹងមីងជឿថានៅក្នុងសម័យខ្មែរក្រហមរយៈពេលបីឆ្នាំហ្នឹង        មីងជឿថាមានប្រជាជនអត់មាន បាយឬក៏ប្រជាជនស្លាប់ទេ?

អ៊ីម  :  មាន   ជឿថាមានច្រើន   ជាពិសេសក្រុមគ្រួសារខ្ញុំហ្នឹង   បើយើងទៅធ្វើការបានគេឲ្យអង្ករហូប បើអត់ទៅធ្វើការបានទេ  យើងអត់បានអង្ករនិងបានបាយហូបទេ ។

វណ្ណៈ  ចឹងមីងជឿថា  មានប្រជាជនស្លាប់ដោយអត់បាយ  ស្លាប់គេយកទៅវៃចោលដែរ?

អ៊ីម  :  ចាស ។

វណ្ណៈ  ចឹងខ្ញុំសួរមីងទៀតថាការដែលប្រជាជនស្លាប់ចឹងមីងគិតថាហ្នឹងថ្នាក់លើបានដឹងដែលឬអត់?

អ៊ីម  :  ថ្នាក់លើដឹងក៏មិនដឹងជាដោះស្រាយថាយ៉ាងម៉េចវាជ្រុលហើយ ។

វណ្ណៈ  ចឹងថ្នាក់លើដូចជាតា  ប៉ុល  ពត  តា  ខៀវ  សំផន  តា  អៀង  សារី  ចឹងមីងគិតថាពួកហ្នឹងមាន បានដឹងការស្លាប់របស់ប្រជាជននៅតាមជនបទដែលអត់?

អ៊ីម  :  ចាស!  ឧទាហរណ៍ដូចជាខ្លួនខ្ញុំផ្ទាល់ចឹងណាស់  ក្នុងរោងចក្រហ្នឹងគឺតម្បាញ២៤ម៉ោង ។

វណ្ណៈ   បាទ ។

អ៊ីម  :  អត់មានឲ្យសម្រាកទេ  ផ្លាស់ប្តូគ្នាក្នុងម្នាក់២ម៉ោងចេញ២ម៉ោងចូលអត់មានពេលដេកទេ  ចេញមកពលកម្មទៀត ។

វណ្ណៈ   បាទ ។

អ៊ីម  :  ដល់ពេលកម្មចឹងទៅតម្បាញហ្នឹងថាយកក្រណាត់ទៅឲ្យប្រជាជន    តែដូចសម័យឥឡូវគេថាក្បត់ចឹងណាស់ ។

វណ្ណៈ   បាទ ។

អ៊ីមៈ   យកក្រណាត់ទាំងឡានទាំងកប៉ាល់ទៅចាក់ទឹកអាស៊ីតចោលកណ្ដាលទន្លេដុយអស់    ដូចនេះប្រជាជនអត់មានខោអាវស្លៀក ។

វណ្ណៈ   ហេតុអីបានជាមីងដឹងថា ខោអាវយកទៅចាក់ទឹកអាស៊ីតចោល?

អ៊ីម  :  ចុះបើឃើញដឹកទាំងកប៉ាល់ទៅមិនបានឃើញដល់ប្រជាជន ។

វណ្ណៈ   ចឹងតាមពិតមីងគិតទេ មីងអត់មានឃើញផ្ទាល់ទេ?

អ៊ីម  :  ឃើញដឹកទាំងទូកប៉កចាយទៅ ។

វណ្ណៈ   ចឹងមីងឃើញដឹកទាំងកប៉ាល់មែន?

អ៊ីមៈ   ចាស ។

វណ្ណៈ   ចឹងមីងមិនដឹងថាគេដឹកទៅណាទេមែនទេ?

អ៊ីម  :  ដឹកយកទៅឲ្យប្រជាជននៅក្នុងសហករណ៍ ។

វណ្ណៈ   ចឹងមីងហេតុអីបានដឹងថា គេចាក់ទឹកអាស៊ីត?

អ៊ីម  :  មានអ្នកទៅហើយស្គាល់គ្នាចឹងគេនិយាយ ។

វណ្ណៈ   តាមពិតគេដឹកទៅប្រទេសចិនទេ មីងអត់ដឹង?

អ៊ីម  :  អត់ទេ ដឹកទៅតាមសហករណ៍ ដល់ពេលពួកខ្ញុំចុះពីកាលមានទឹកឡើងលិចពោតអីចឹងទៅ  កាលហ្នឹងគេឲ្យកម្មករទៅជួយកាច់ពោត ។

វណ្ណៈ   បាទ ។

អ៊ីម  :  ដល់ហើយគាត់សួរ កុំអីពួកខ្ញុំក៏អត់ដឹងដែរ គាត់សួរថាពួកមីងនាងឯងមានស្លៀកពាក់ត្រឹមត្រូវល្អចំណែកពួកគាត់អត់មាន ហើយខាងខ្ញុំសួរទៅពួកគាត់វិញ ។

វណ្ណៈ   ចឹងកាលហ្នឹងតម្បាញបានហើយអង្គការប្រាប់ថាយកទៅឲ្យប្រជាជន?

អ៊ីម  :  ចាស ។

វណ្ណៈ   ចឹងតាមពិតយកចាក់ចោលណា?

អ៊ឹម ៖ យកចាក់ចោលក្នុងទឹកទន្លេមេគង្គ ទន្លេបាសាក់ ។

វណ្ណៈ អ្នកណាជាអ្នកប្រាប់មីង?

អ៊ឹម ៖ គេជាអ្នកបើកបរ ។

វណ្ណៈ អ្នកបើកបរគេមានស្គាល់ឈ្មោះទេ?

អ៊ឹម ៖ អត់ស្គាល់ទេ ។

វណ្ណៈ និយាយប្រាប់នៅពេលណា?

អ៊ឹម ៖ និយាយប្រាប់នៅពេលរត់យួនហ្នឹង គាត់ថាអាណិតប្រជាជន ។

វណ្ណៈ ចឹងប្រាប់នៅពេលរត់យួនទេ?

អ៊ឹមៈ ចាស ។

វណ្ណៈ ចឹងកាលជំនាន់ខ្មែរក្រហមមិនហ៊ាននិយាយទេ?

អ៊ឹម ៖ អត់ទេ កាលហ្នឹងគេមិនឲ្យទាក់ទងគ្នាទេប្រុសស្រីនោះ ។

វណ្ណៈ ចឹងប្រុសស្រីមិនអាចទាក់ទងគ្នាបានទេ?

អ៊ឹម ៖ ចាស! សូម្បីបងប្អូនបង្កើតមិនអាចទាក់គ្នាបានដែរ សូម្បីយើងស្គាល់គ្នាយើងឲ្យចំណីគ្នាហូបមិន
បានដែរ គេមិនឲ្យនៅជាមួយគ្នាដែរ ។

វណ្ណៈ ចឹងជំនាន់ប៉ុល ពតហ្នឹងស្រីប្រុសគេមិនទាក់ទងគ្នាទេ បើគេដឹងគេកសាង?

អ៊ឹមៈ ចាស!គេកសាង ។

វណ្ណៈ ចឹងគេអាចចាប់ខ្លួនអីចឹងដែរ?

អ៊ឹមៈ គេកសាងហើយបើយើងមិនតាមគេ គេដកយើងយកទៅស្ទូងនៅតាមស្រុកស្រែទៅណាស់ ។

វណ្ណៈ បាទ ។

អ៊ឹមៈ ដូចជាខ្លួនខ្ញុំជាក់ស្តែងចឹងឯង ។

វណ្ណៈ ចឹងមីងជឿថាស្រូវអង្ករតាមពិតខ្ញុំសួរប្រជាជនដែលស្រូវអង្ករធ្វើបានច្រើន?

អ៊ឹមៈ ចាស!តែមិនដឹងជាគេយកទៅណា ។

វណ្ណៈ តែប្រជាជនអត់មានបានហូបទេ ប្រជាជនហូបមិនឆ្អែតអីចឹងចឹងមីងគិតថាស្រូវអង្ករហ្នឹងចេញ
ទៅខាងណាដែរ?

អ៊ឹម ៖ ខ្ញុំអត់ដឹង ព្រោះខ្ញុំមិនបាននៅសហករណ៍ផង ។

វណ្ណៈ តែខោអាវមីងអត់បានដឹកទៅណាទេ?

អ៊ឹម ៖ ខោអាវអត់បានទៅដល់ប្រជាជនទេ ។

វណ្ណៈ តែកាលហ្នឹងមីងមិនបានដឹងមិនអាចនិយាយបានទេ?

អ៊ីម ៖ ចាស ។

វណ្ណៈ តែខ្លះនិយាយថា ដូចជាស្រូវនាំចេញទៅប្រទេសចិន ខាងតម្បាញអីមានយកទៅចិន?

អ៊ីម ៖ ចាស ។

វណ្ណៈ យើងទទួលបានមកវិញដូចជាចបកាប់អីហ្នឹង ព្រោះយើងកាលហ្នឹងមានទំនាក់ទំនងជាមួយចិន?

អ៊ីម ៖ ចាស ។

វណ្ណៈ កាលនោះប្រទេសចិនមានទូតនៅជាមួយយើងរហូត?

អ៊ីម ៖ ចាស! យើងវែកដីធ្វើទំនប់ធ្វើស្រែធ្វើភ្លឺហ្នឹង ខ្ញុំកាលសម័យហ្នឹងពូៗគាត់ស្គាល់មើលខ្ញុំមានប្រជុំយចឹង គាត់ផ្ញើរអីវ៉ាន់មកឲ្យខ្ញុំ ដល់ហើយខ្ញុំថាបងឯងបានទទួលហើយបងឯងហូបទៅ ។

វណ្ណៈ បាទ ។

អ៊ីម ៖ តែខ្ញុំអត់បានស្គាល់គេដង ខ្ញុំអត់ទទួលខ្ញុំអត់យកទេ ដល់ហើយគេតាមដានខ្ញុំគេយកខ្ញុំទៅស្ទូងស្រូវរយៈបីខែទៅបួនខែ ។

វណ្ណៈ បាទ ។

អ៊ីម ៖ ហើយដល់ពេលយើងមកដល់កន្លែងវិញ អត់មានពូៗមកលេងទេ ។

វណ្ណៈ បាទ ។

អ៊ីម ៖ ដល់ចឹងទៅគេចេះតែទុកខ្ញុំ ដូចអត់ជាកើតហេតុអីនៅក្នុងរោងចក្រចឹងទៅណាស់ ។

វណ្ណៈ ចឹងកាលហ្នឹងមីងជឿថាមានគេសម្លាប់មនុស្សនៅក្នុងជំនាន់ហ្នឹងមានគេចាប់មនុស្សក្នុងកងអីចឹង?

អ៊ីម ៖ ចាស ។

វណ្ណៈ ចឹងមីងគិតថាថ្នាកលើបានដឹងដែរឬមួយយ៉ាងម៉េច?

អ៊ីម ៖ ខ្ញុំមិនដឹងដែររឿងហ្នឹងគេចាប់ចឹង ។

វណ្ណៈ ចឹងមីងគិតថាថ្នាក់លើជាអ្នកបញ្ជាឬយ៉ាងម៉េច?

អ៊ីម ៖ មិនហ៊ានថា ។

វណ្ណៈ ចឹងមីងគិតថាថ្នាក់លើបានធ្វើឲ្យប្រជាជនស្លាប់ច្រើនចឹងគួរតែទទួលកំហុសចេញសារភាពឬយ៉ាងម៉េច?

អ៊ីម ៖ ចាស! គាត់នៅក្នុងហ្នឹងគាត់ជាអ្នកដឹកនាំមួយឧទាហរណ៍ដូចជាមេគ្រួសារមួយ កូនទៅធ្វើខុសតែម៉ែឪមិនដឹង ។

វណ្ណៈ បាទ ។

អ៊ីម ៖ ដល់ដឹងក្រោយមកហៅកូនមកនែនាំតែវាហួសពេលទៅហើយ ។

វណ្ណៈ ចឹងមីងគិតថាចឹង?

អ៊ុម ៖ ចាស! អាហ្នឹងខ្ញុំគិតថាក្រុមគ្រួសារតូច ។

វណ្ណៈ ចឹងមីងគិតថាគាត់មិនបានដឹងដូចជាក្រុមគ្រួសារយើងដែរ?

អ៊ុម ៖ ចាស ។

វណ្ណៈ ចឹងមានន័យថាគាត់មិនបានដឹងពីការស្លាប់របស់ប្រជាជននៅតាមភូមិទេ?

អ៊ុម ៖ ចាស! ដល់បានដឹងហួសពេលនិយាយ ។

វណ្ណៈ ដល់ដឹងហួសពេល?

អ៊ុមៈ ចាស ។

វណ្ណៈ ចឹងប្រហែលជាគាត់មិនបានដឹង?

អ៊ុម ៖ ឬមួយគាត់បានដឹងដែរ យើងមិនហ៊ានសន្និដ្ឋាន តែមិនដែលមនុស្សស្លាប់មួយទាំងមូលមិនដឹង ។

វណ្ណៈ បាទ ។

អ៊ុម ៖ តែខុសអ្នកដឹកនាំ ។

វណ្ណៈ ចឹងដូចជាសម័យឥឡូវហ្នឹង ឧទាហរណ៍បើសម្តេចហ៊ុន សែនដឹកនាំប្រជាជនស្លាប់ច្រើនក៏ជាកំហុសរបស់គាត់ដែរ?

អ៊ុម ៖ ចាស! គាត់អ្នួលធំជាងគេ ។

វណ្ណៈ ចឹងគាត់ត្រូវមើលឲ្យដិតដល់មើលថាប្រជាជនហ្នឹងស្លាប់ដោយសារមូលហេតុអី?

អ៊ុម ចាស ។

វណ្ណៈ ចឹងនៅសម័យខ្មែរក្រហមមានប្រជាជនស្លាប់ច្រើនណាស់បើយើងប្រៀបធៀបជាមួយប្រទេសគេដែលមានសម្លាប់មនុស្សដូចគ្នា?

អ៊ុម ៖ ចាស ។

វណ្ណៈ តែប្រជាជនគេច្រើនគេស្លាប់តិចជាងយើងទេ ។

អ៊ុម ៖ ចាស ។

វណ្ណៈ ថ្វីត្បិតតែគេស្លា៧ទៅ៨លាននាក់ ប៉ុន្តែប្រជាជនគេមាន១០០លាននោះ?

អ៊ុមៈ ចាស ។

វណ្ណៈ ហើយប្រជាជនយើងមានតែ៧លានស្លាប់អស់ជាមួយលានច្រើនណាស់?

អ៊ុមៈ ចាស ។

វណ្ណៈ ហើយការស្លាប់ហ្នឹងមិនមែនតែមួយខេត្តឬមួយស្រុកទេ ស្លាប់ទូទាំងប្រទេស?

អ៊ុមៈ ស្លាប់ទូទាំងប្រទេស ។

វណ្ណៈ បើនិយាយទៅប្រព័ន្ធដឹកនាំតែមួយទេ?

អ៊ឹមៈ ចាស!ចឹងបានថាហ្នឹង ។

វណ្ណៈ ចឹងមីងគិតថាមេដឹកនាំខ្មែរក្រហមមិនបានដឹងឬមីងមិនហ៊ានគិត?

អ៊ឹម ៈ ចាស!មិនដឹង ។

វណ្ណៈ ចឹងមីងសន្និដ្ឋានមិនបាន?

អ៊ឹមៈ ចាស!តែខុសៗគាត់អ្នកដឹកនាំដែរ ។

វណ្ណៈ តែមីងនិយាយមិញថាប្រៀបធៀបនិងគ្រួសារមួយថាអត់ដឹងកូនធ្វើខុស?

អ៊ឹមៈ ចាស ។

វណ្ណៈ ធ្វើខុសហើយស្តាយក្រោយ?

អ៊ឹមៈ ចាស!ហួសពេលនិយាយ ។

វណ្ណៈ ចឹងប្រហែលជាមិនបានដឹងធ្វើឲ្យស្លាប់ច្រើន?

អ៊ឹមៈ ចាស ។

វណ្ណៈ មីងចង់ឲ្យពួកគាត់សារភាពទោសកំហុសហ្នឹងអត់ចិត្តមីងវិញ ចង់ឲ្យគាត់ប្រាប់រឿងរ៉ាវហ្នឹងអត់ប្រាប់រឿងរ៉ាវដែលគាត់ធ្វើខុសហ្នឹងអត់ឬមិនចាំបាច់ឲ្យគាត់ប្រាប់ទេ?

អ៊ឹម ៈ ខ្ញុំមិនហ៊ានថាដែរ ព្រោះខ្ញុំមិនដឹងរឿងហ្នឹងគាត់បានដឹងឬមិនដឹង តែខ្ញុំប្រៀបធៀបនៅក្រុមគ្រួសារតូច ។

វណ្ណៈ ចឹងមីងស្រុកយើងឥឡូវចង់ឲ្យមានការផ្សះផ្សាគ្នា យើងអត់មានប្រកាន់ថាខាងម៉ាខ្សែជាអតីតខ្មែរក្រហមឬប្រជាជនខាងក្នុងខាងក្រៅអីទេ យើងសព្វថ្ងៃជាខ្មែរតែមួយ ។

អ៊ឹម ៈ ចាស ។

វណ្ណៈ យើងចង់រាប់អានគ្នាទៅវិញទៅមក ។

អ៊ឹម ៈ ចាស ។

វណ្ណៈ ហើយយើងស្រាវជ្រាវចង់ដឹងប្រវត្តិនេះគឺយើងចង់បានឲ្យចូលគ្នាកាន់តែជិត?

អ៊ឹម ៈ ចាស ។

វណ្ណៈ មានន័យថាលែងឲ្យមានការបែងចែក?

អ៊ឹម ៈ ចាស ។

វណ្ណៈ មិនចង់ឲ្យមានការបែងចែកថាអ្នកនោះជាខ្មែរក្រហមអ្នកនេះមិនមែនជាខ្មែរក្រហម?

អ៊ឹម ៈ ចាស ។

វណ្ណៈ ចឹងការផ្សះផ្សានៅឆ្ងាយពីគ្នាចឹងមីងគិតថាខាងនោះនៅភ្នំពេញខាងនេះនៅម៉ាខ្សែអីចឹងមីងគិតថាការផ្សះផ្សាហ្នឹងអាចមានល្បឿនលឿនឬមួយយ៉ាងម៉េចដែរ?

អ៊ឹម ៈ ខ្ញុំចង់ឲ្យមានការសាមគ្គីគ្នាស្និទ្ធស្នាលដូចបងប្អូនចឹងទៅណាស់ ។

វណ្ណៈ បាទ ។

អ៊ឹមៈ ហ្នឹងចិត្តខ្ញុំមិនឲ្យមានការបែងចែក ដូចជាបងជីដូនមួយខ្ញុំហ្នឹង ខ្ញុំទៅលេងគាត់ហៅខ្ញុំ ថាអើមី ខ្មែរក្រហមឯងតិចទៀតគេមកចាប់ហើយ គាត់លេងជាមួយខ្ញុំ ។

វណ្ណៈ ចឹងមីងមានប្រកាន់គាត់ទេ?

អ៊ឹម ៈ ខ្ញុំអត់ទេ គាត់ហៅយ៉ាងម៉េចហៅទៅ ព្រោះខ្ញុំមិននៅស្រុកហ្នឹងផង ខ្ញុំមកនៅនេះហើយ ។

វណ្ណៈ ចឹងចង់ផ្សះផ្សាមិនឲ្យប្រកាន់គ្នាទៀត?

អ៊ឹម ៈ ចាស!ចង់កុំឲ្យប្រកាន់គ្នាតទៅទៀត ខ្មែរនៅក្នុងខ្មែរនៅព្រំដែនចឹង ។

វណ្ណៈ បាទ!ចឹងមិនឲ្យគិតខ្មែរក្នុងក្រៅអីទៀត?

អ៊ឹមៈ ចាស ។

វណ្ណៈ ចឹងមីងដូចថាមីងធ្លាប់បានចូលបំរើបដិវត្តន៍តាំងពីឆ្នាំ៧៤រហូតដល់មីងបែកស្រុកទេស បែកឪពុកម្ដាយបងប្អូនមករស់នៅក្នុងព្រៃចឹងមីងគិតថាមកជួបជីវិតបែបហ្នឹង នៅពេលដែលមីងដឹងក្ដីមកជួបជិវិតបែបហ្នឹង?

អ៊ឹមៈ ចាស ។

វណ្ណៈ តើមកដល់ឥឡូវមីងគិតថាមានការខកចិត្តអីដែរ មិនគួរមកដេកព្រៃមិនគួរមកបែកបងប្អូនអីចឹង?

អ៊ឹម ៈ គិតចឹងដែរ តែធ្លាប់មកនៅទីនេះហើយមិនចង់ទៅនៅស្រុកវិញ ម៉ែខ្ញុំឲ្យខ្ញុំមកនៅស្រុកវិញដែរ តែខ្ញុំមិនចេះនៅរាកទៅនោះទិញគេ រកទៅនេះទិញគេ បើយើងនៅនេះមានដីមានកន្លែងដាំស្លឹកគ្រៃដាំដីដាំស្ពៃហូបមានស្វាយមានដូងអីចឹងទៅណាស់ ។

វណ្ណៈ បាទ ។

អ៊ឹមៈ ដល់ទៅដល់នោះទិញគេសព្វគ្រប់មិនចេះនៅ ។

វណ្ណៈ ចឹងមីងមិនមានចិត្តទៅរស់នៅស្រុកកំណើតវិញទេ?

អ៊ឹម ៈ មិនចង់ ។

វណ្ណៈ ចឹងស្រឡាញ់ដីនៅម៉ាឡៃ?

អ៊ឹម ៈ ចាស!សើច.... ។

វណ្ណៈ ចឹងមកដល់បច្ចុប្បន្ននេះមានអង្គការស៊ីម៉ាក់មកជួយដោះមីនអីចឹងនៅពេលដែលមីងធ្វើដំណាំបានអីចឹងមីងត្រូវដោះដូរជាមួយខាងណាសព្វថ្ងៃ?

អ៊ឹម ៈ មានអ្នកមកពីក្នុងមកទិញ កាលនៅតែពួកខ្ញុំមានខាងថៃមកទិញ ។

វណ្ណៈ ចឹងកាលជំនាន់៧៩ដោះដូជាមួយថៃ?

អ៊ុម  :  ចាស!៧៩រហូតដល់៩៣-៩៤ដោះដូរជាមួយថៃ ដល់៩៦-៧៩បានមានអ្នកចូលមកពីក្នុង ។

វណ្ណៈ  ចឹងដោះដូរជាមួយថៃ?

អ៊ុមៈ  ចាស!តែដល់ក្រោយមកមានខ្មែរមកវិញមានថៃខ្លះមានខ្មែរខ្លះ ។

វណ្ណៈ  ចឹងមានដោះដូរជាមួយថៃជាមួយខ្មែរខាងក្នុង?

អ៊ុមៈ  ចាស ។

វណ្ណៈ  ចឹងឥឡូវប្រជាជននៅតំបន់ហ្នឹងគេប្រកបមុខរបរអ៊ីជាសំខាន់?

អ៊ុម  :  មានដំឡូង ពោត សណ្ដែកបាយ សណ្ដែកសៀង ។

វណ្ណៈ  ចឹងស្រូវ?

អ៊ុម  :  ស្រូវមានតិចតួច គេមានដីច្រើនបានច្រើនយើងមានដីតិចបានតិច ។

វណ្ណៈ  ចឹងភាគច្រើនដំណាំ?

អ៊ុម  :  ចាស ។

វណ្ណៈ  ចឹងមីងមានដីដំណាំដូចជាពោត សណ្ដែកដែរ?

អ៊ុម  :  ខ្ញុំមានតិចតួច តែយើងធ្វើទៅយើងធ្វើមួយឆ្នាំចឹងទៅវាខុសប៉ះរាំងស្ងួតចឹងទៅខូច ឆ្នាំនេះខាតពោតអស់ជិត២០០០០ហើយមកដល់សណ្ដែកបានរួចខ្លួន កាលខ្ញុំធ្វើការឆ្នាំ៩៦មានចំពាក់គេ ៩៦អីកាលឆ្នាំ២០០០ជាងហើយ ។

វណ្ណៈ  កាលឆ្នាំ២០០៦ ឥឡូវ២០១០ហើយ?

អ៊ុម  :  ឆ្នាំ២០០៥ ខ្ញុំជំពាក់គេ ជំពាក់គេ៤០០០០ជិត៥០០០០បាត តែកូនខ្ញុំទៅស៊ីឈ្នួលនៅប្រទេសថៃមួយឆ្នាំបានយកមកសងគេ ។

វណ្ណៈ  បាទ ។

អ៊ុម  :  បានយកមកសងគេហើយ ដល់ហើយកូនខ្ញុំវាខាតរៀនខាតសូត្រដល់មកវិញវាសុំខ្ញុំរៀន ។

វណ្ណៈ  បាទ ។

អ៊ុម  :  ខ្ញុំឲ្យទៅរៀនវិញទៅឥឡូវហ្នឹងវារៀននៅភ្នំពេញ ។

វណ្ណៈ  ចឹងកូនមីង៥នាក់ហ្នឹងបានរៀនទាំងអស់?

អ៊ុម  :  រៀនទាំងអស់ តែឥឡូវឈប់បីនាក់ហើយនៅសល់តែពីរទេ ។

វណ្ណៈ  ឈប់រៀនដោយសារអី?

អ៊ុម  :  ឈប់ដោយសារម៉ែក្រពេក ។

វណ្ណៈ  ចឹងឈប់ដោយសារជីវភាព?

អ៊ុមៈ  ចាស ។

វណ្ណៈ  បីហ្នឹងឈប់ថ្នាក់ទីប៉ុន្មានខ្លះ?

អ៊ឹម  :  មួយឈប់ថ្នាក់ទី៤  ពីរទៀតឈប់ត្រឹមថ្នាក់ទី៧ ។

វណ្ណៈ  ចឹងនៅសល់ពីរនាក់ទៀតរៀនដល់ណា?

អ៊ឹម  :  មួយរៀននៅភ្នំពេញបានឆ្នាំទី៣ហើយ ។

វណ្ណៈ  រៀនផ្នែកអី?

អ៊ឹម  :  វាជាប់អាហាររូបករណ៍ផ្នែកច្បាប់ ។

វណ្ណៈ  រៀនបានផ្នែកច្បាប់នៅភ្នំពេញ?

អ៊ឹមៈ  ចាស ។

វណ្ណៈ  ស្រីឬប្រុស?

អ៊ឹម  :  ប្រុស ។

វណ្ណៈ  ហើយមួយទៀត?

អ៊ឹម  :  មួយទៀតថ្នាក់ចឹងថ្នាក់ទី៩ ។

វណ្ណៈ  មួយទៀតថ្នាក់ទី៩?

អ៊ឹមៈ  ហ្នឹងឪវាស្លាប់នៅក្នុងពោះបាន៤ខែ ។

វណ្ណៈ  មានមួយទៅភ្នំពេញ?

អ៊ឹមៈ  ចាស ។

វណ្ណៈ  មួយទៀតរៀននៅណា?

អ៊ឹម  :  រៀននៅម៉ាឡៃយើងនេះ ។

វណ្ណៈ  ចឹងខ្ញុំចង់សួរមីងទាក់ទងនិងការកាត់ទោសមេដឹកនាំខ្មែរក្រហមធំកំពូល១ប៉ុន្មាននាក់ហ្នឹង?

អ៊ឹមៈ  ចាស ។

វណ្ណៈ  តែចិត្តមីងជាទស្សនៈរបស់មីង  ដែលមីងបញ្ចេញផ្ទាល់នោះណាស់  ចង់និយាយថាមានការកាត់ទោសហ្នឹងត្រឹមត្រូវទេឬក៏មិនត្រឹមត្រូវទេ?

អ៊ឹម  :  វាមិនមែនខុសតែគាត់ទេ  គឺខុសទាំងអស់គ្នា ។

វណ្ណៈ  ខុសទាំងអស់គ្នាតែនៅក្នុងច្បាប់បើមីងគិតថាខុសទាំងអស់គ្នាហ្នឹងចាប់មួយប្រទេស?

អ៊ឹមៈ  ចាស ។

វណ្ណៈ  ព្រោះអ្នកណាក៏ជាខ្មែរក្រហមដែរ  ឲ្យតែមានអាយុប្រហាក់ប្រហែលមីង៤០ជាង៥០ជាង?

អ៊ឹម  :  ចាស!សើច..។

វណ្ណៈ  តែក្នុងច្បាប់អន្តរជាតិគេគិតថាប្រជាជនតូចតាចហ្នឹងស្តាប់បញ្ជាលើ?

អ៊ុម ៖ ចាស ។

វណ្ណៈ ចឹងគេកាត់តែអ្នកដឹកនាំកំពូលៗលើទេ?

អ៊ុម ៖ ចាស ។

វណ្ណៈ ចឹងបើតាមចិត្តរបស់មីងវិញ គួរតែកុំមានតុលាការឬគួរតែមានតុលាការ?

អ៊ុម ៖ ខ្ញុំមិនសូវចេះទេត្រង់ហ្នឹង ។

វណ្ណៈ បាទ ។

អ៊ុម ៖ តែប្រទេសមួយៗត្រូវតែមានច្បាប់ ។

វណ្ណៈ ចឹងមីងគិតថាចឹង?

អ៊ុម ៖ ចាស ។

វណ្ណៈ ចឹងមីងគិតថាការកាត់ទោសហ្នឹងធ្វើឲ្យការផ្សះផ្សារងាកចេញពីគ្នាឬមួយមីងគិតថាមិនអីទេ ពេលមានតុលាការកាត់ទោសនេះ?

អ៊ុម ៖ ផ្សះផ្សាសាមគ្គីគ្នាទៅកុំឲ្យមានបញ្ហាអីទៅមុខទៀត យើងចេះជួយមតិគ្នាទៅ ដូចថាអ្នកដឹកនាំមួយខុសយើងចេះជួយគ្នាទៅវិញទៅមកទៅ ។

វណ្ណៈ បាទ ។

អ៊ុម ៖ អាហ្នឹងជាទស្សនៈរបស់ខ្ញុំ ។

វណ្ណៈ បាទ ។

អ៊ុម ៖ ចាស ។

វណ្ណៈ ចឹងមីងមានចង់និយាយអ៊ីបន្ថែមទៀតទេ ដែលខ្ញុំអត់បានសួរនាំអីមានចង់និយាយហេតុផលអីផ្ទាល់ខ្លួនឬមួយចង់និយាយអី មីងអាចនិយាយបាន ខ្ញុំអត់មានសំនួរសួរមីងទៀតទេ?

អ៊ុម ៖ សើច....អត់មានចង់និយាយអីទៀតទេ ។

អ៊ុម៖ ខ្ញុំចង់សួរតែប៉ុននេះទេ កូនខ្ញុំរៀនច្បាប់ចឹងចេញមកខ្វាចអត់មានការងារធ្វើ ។

វណ្ណៈ រឿងហ្នឹងឥឡូវគេត្រូវការអ្នកចេះដឹងដែរ នៅពេលយើងរៀនចប់ចឹងមានការងារណាគេជ្រើសរើសយើងដាក់ទៅ ចឹងនៅកន្លែងខ្ញុំត្រូវការជ្រើសរើសអ្នកស្មគ្រចិត្តរាល់ឆ្នាំអីចឹងចាំដាក់ទៅ ។

អ៊ុម៖ ចាស ។

វណ្ណៈ គេមានបិតតាមសាលាប្រហែលជាកូនមីងបានឃើញដែរ ។

អ៊ុម៖ មិនដឹងជាយ៉ាងម៉េចគេនៅរៀននោះ ។

វណ្ណៈ ចឹងមីងមានចង់និយាយអីទៀតទេ?

អ៊ុម៖ អត់មានចង់និយាយអីទេ ។

វណ្ណៈ   ចឹងខ្ញុំអរគុណមីងហើយ ។

អ៊ឹម  ៖  ចាស ។

**«ចប់»**